# ថ្ងៃកំណើតប្រចាំឆ្នាំ

## ១-មនុស្សកើតឆ្នាំជូត

### ថ្ងៃអាទិត្យ

មានគេបំណងរុកកួនរឿយៗ ជាមនុស្សត្រូវគេឥច្ឆាច្រើនក្នុងពេលដែលខ្លួនបានសុខសំបូរ មានការពុំស្រួល តែអំពីអ្នកប្រកបការរួម លំបាកធ្វើខ្លួនឱ្យជាទីកោតសរសើរនៃអ្នកដទៃ ជាមិត្តរួមចិត្តជាមួយអ្នកកើតថ្ងៃព្រហស្បតិ៍ មានសត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃច័ន្ទ

សំបូរសប្បាយច្រើន រួមរស់ជាមួយនឹងគេ គេរមែងលបស្រឡាញ់ រូបស្អាតសំសួន សំដីជូរចត់ ច្រើនចេះលកលៃ កាញ់គ្នេ រួមមិត្តជាមួយមនុស្សកើតថ្ងៃពុធ សត្រូវរួមជាមួយអ្នកកើតថ្ងៃព្រហស្បតិ៍ ។

### ថ្ងៃអង្គារ

ច្រើនមានទុក្ខទោសព្រោះនាយ ឬអ្នកធំបញ្ជាអាក្រក់ ច្រើនលង់គំនិតព្រោះជឿសម្ដីគេ លំបាកក្នុងការធ្វើដំណើរ ឆ្ងាយ គេរាប់អានតែមាត់ ចិត្តគេប៉ងតែប្រទូស្ដ មិត្តជាមួយមនុស្សកើតថ្ងៃសុក្រ មានសត្រូវជាមួយមនុស្សកើតថ្ងៃ ព្រហស្បតិ៍ ។

### ថ្ងៃពុធ

តែងប្រមូលរឿងទុក្ខព្រួយមកជាអារម្មណ៍ អភ័ព្វ ច្រើនចចេសរឹង ឆាប់ក្អក់ក្អាញ់ កំណាញ់ចំពោះខ្លួន មិត្តជាមួយមនុស្សកើតថ្ងៃច័ន្ទ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

### ថ្ងៃព្រហស្បតិ៍

ត្រូវបានគេជួយស្រោចស្រង់ឱ្យផុតពីវេទនា រួមរស់ជាមួយអ្នកធំបានល្អក្រៃពេក មនុស្សខ្សត់ទ្រព្យ ឬអំណាច ច្រើនរំលោភមើលងាយ មិត្តជាមួយមនុស្សកើតថ្ងៃអាទិត្យ សត្រូវជាមួយមនុស្សកើតថ្ងៃសៅរ៍ ។

### ថ្ងៃសុក្រ

បានបរិបូរទៅដោយគ្រឿងឧបភោគ-បរិភោគផ្សេងៗ អ្នកធំរមែងផ្ដល់ធនធានឱ្យរឿយៗ មានគេស្ងួនគ្រងយ៉ាង ថ្នាក់ថ្នម មិត្តជាមួយមនុស្សកើតថ្ងៃអង្គារ សត្រូវគ្នានឹងអ្នកកើតថ្ងៃច័ន្ទ ។

### ថ្ងៃសៅរ៍

ច្រើនបានជាអ្នកធំ មានបុណ្យសក្តិខ្ពស់ សំបូររុងរឿងដោយយសបរិវារចោមរោម បានសាន្តសុខនិរទុក្ខភ័យ មិត្តជាមួយមនុស្សកើតថ្ងៃជារាហ៊ូ (ដែលពោលថាថ្ងៃជារាហ៊ូរនេះ លោកកំណត់យកតាមបែបអដ្ឋគ្រោះក្នុងទីនេះ មិនមានថ្ងៃជារាហ៊ូទេ ដូច្នេះកំណត់យកថ្ងៃកំណើតពានលើថ្ងៃដែលរាហ៊ូចាប់ព្រះសុរិយា) សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

# ២-មនុស្សកើតឆ្នាំឆ្លូវ

## ថ្ងៃអាទិត្យ

ច្រើនព្រហើនកោងកាចណាស់ ក្លៀវក្លាទៅដោយកម្លាំងកាមរោគ អភ័ព្វក្នុងការចងមេត្រីភាព ជាមនុស្សកំសត់ធ្វើល្អដល់គេបានតែផលគ្រោតគ្រាតតបវិញ មិត្តជាមួយអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

## ថ្ងៃចន្ទ

មានមនុស្សចោមរោមស្រឡាញ់យកជាមិត្តមេត្រីច្រើន ធ្វើល្អដល់គេតែបន្តិចបន្តួច អាចបានលទ្ធផលលូតលាស់ ប្រសើរល្អ ចូលចិត្តស្តាប់ពាក្យផ្អែមល្ហែម មិត្តជាមួយមនុស្សកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ថ្ងៃអង្គារ

មានសេចក្តីនឿយព្រួយច្រើន ធ្វើការមិនសូវបានសម្រាកកម្លាំង មានទ្រព្យមិនសូវចេញចាយឡើយ គ្រឿងបរិភោគរលីបរលាប មានមិត្តជាមួយមនុស្សកើតថ្ងៃសុក្រល្អ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ថ្ងៃពុធ

មិនសូវបានឃើញវត្ថុចម្លែកចិត្តញឹកញាប់ទេ ទៅកាន់ទីកំសាន្តឆ្ងាយរមែងបានទុក្ខលំបាកដោយប្រការផ្សេងៗ ប្រកបអាជីពតែទៅលើការបង់ទុនសូន្យចំណេញ មិត្តជាមួយមនុស្សកើតថ្ងៃអង្គារ សត្រូវជាមួយនឹងអ្នកកើតថ្ងៃសៅរ៍បន្តិច បន្តួច ។

## ថ្ងៃព្រសហ្បតិ៍

ជាទីស្រឡាញ់រាប់អាននៃមនុស្សទូទៅ មានគេកោតគោរពបូជារឿយៗ មានសម្បត្តិទ្រព្យស្តុកស្តម្ភ មិត្តល្អជាមួយមនុស្សកើតថ្ងៃសុក្រ សត្រូវជាមួយអ្នកកើតថ្ងៃសៅរ៍ ។

## ថ្ងៃសុក្រ

ច្រើនជាប់ជំពាក់នឹងកង្វល់ ធ្វើការច្រើន នឿយហត់ច្រើន ទើបមានសុខភាព ឱ្យគេធ្វើជួសចេះតែមិនសូវអស់ចិត្ត លោភលន់ដោយកម្លាំង មិត្តល្អជាមួយមនុស្សកើតថ្ងៃអង្គារ សត្រូវជាមួយអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសៅរ៍

ត្រូវជួបប្រទះនឹងសេចក្តីវិបត្តិញឹកញាយ មានចោរកម្មតាមឈ្នានីសរឿយៗ មានទ្រព្យឱ្យគេខ្ចីគេមិនសងវិញ ប្រកបអាជីពតែងបានធ្លោយខាងដើមជាដរាប មិត្តល្អជាមួយមនុស្សកើតថ្ងៃជារាហ៊ូ សត្រូវរួមនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ៣-មនុស្សកើតឆ្នាំខាល

### ថ្ងៃអាទិត្យ

ស្រឡាញ់ទីកន្លែងស្ងប់ស្ងាត់ ប្រកបអាជីវកម្មទៅកាន់តំបន់ឆ្ងាយលំបាកណាស់ ជីវិតរស់ដោយការប្រឹងប្រែងរកតាមកម្លាំងជាការមិនទៀងទាត់ មិត្តល្អជាមួយមនុស្សកើតថ្ងៃព្រហស្បតិ៍ សត្រូវរួមអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

ច្រើនមានឧបសគ្គមកស្ទាក់ដំណើរការរីកចំរើន រមែងឱ្យគេកើតពីផលសង្ស័យផ្សេងៗ ដំណើរពេលយប់ច្រើនស្កុន ការជាដាបមិនគួរចាប់កាន់លេងគ្រឿងរហ័ស មិត្តល្អជាមួយមនុស្សកើតថ្ងៃពុធ មានសត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

### ថ្ងៃអង្គារ

ច្រើនមានសេចក្តីរំលោភប្ញស្សាគេ ប៉ិនសន្សំហេតុ មានគំនុំដក់នៅជាប់ លុះតែបានផ្ចាញ់ទើបរលាយ គ្រួសារប្រតិបត្តិមិនចេះត្រូវចិត្ត មិត្តល្អជាមួយមនុស្សកើតថ្ងៃសុក្រ សត្រូវរួមនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

### ថ្ងៃពុធ

មានសន្តានចិត្តធ្ងន់ធ្ងរ ប្រកបការងារបរិសុទ្ធ ធន់ទ្រាំនឹងធម្មជាតិ អធ្យាស្រ័យស្របតាមសម្តី ចូលចិត្តខាងធ្វើ បុណ្យទានមិត្តល្អជាមួយមនុស្សកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច ។

### ថ្ងៃព្រហស្បតិ៍

ធ្លាប់បានទទួលសេចក្តីទុក្ខលំបាកកាលនៅវ័យក្មេង លុះដល់ចំរើនវ័យពេញលក្ខណៈវក់ចិត្តនឹងផ្លូវកាមគុណ ដល់គ្រាក្រោយទើបបានសុខ បានទ្រព្យដោយធម៌ មិត្តល្អនឹងអ្នកកើតថ្ងៃអាទិត្យ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសុក្រ

ច្រើនធ្លាក់ខ្លួនក្នុងគំនរទុក្ខក្តៅ ព្រោះសេចក្តីច្រណែន មានតែចិត្តចង់បាន គ្មានពេលលោះ អភ័ព្វក្នុងការទំនុកបំរុង គេសម្តីនិងទឹកចិត្តឥតចូលផ្លូងគ្នាបាន មិត្តល្អជាមួយអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ

### ថ្ងៃសៅរ៍

ច្រើនមានអ្នកធំមិនធ្លាប់ស្គាល់ជួយទំនុកបំរុងផ្តល់ប្រយោជន៍ មានគេកាន់ជើងជួយឈឺឆ្អាលរឿយៗ បានសេចក្តីតាមអំពើដែលខ្លួនបានប្រព្រឹត្ត មិត្តល្អជាមួយអ្នកកើតថ្ងៃជារាហ៊ូ សត្រូវរួមនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ៤-មនុស្សកើតឆ្នាំថោះ

### ថ្ងៃអាទិត្យ

កាលនៅពីតូចធ្លាប់ជួបប្រទះរឿយៗនូវសេចក្តីក្តៅផ្សារ ប្រកបអាជីវកម្មហាលភ្លៀងហាលកំដៅ ច្រើននឿយហត់ ណាស់ មានចិត្តឆ្មើងឆ្មៃ ដើរឆ្ងាយបានលាភផលប្រសើរ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

ត្រូវបានអ្នកមានសប្បុរសផ្គត់ផ្គង់ ជីវិតរស់នៅក្នុងភាពថ្កើងថ្កាន ចរទៅកាន់ទីជិតឆ្ងាយមានចាស់ទុំតាមមើលការ ខុសត្រូវ មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ។

### ថ្ងៃអង្គារ

ចិត្តសាវ៉ា សម្តីសាបរលាប ធ្វើការច្រើនខ្ជីខ្ជារ អភ័ព្វ ធ្វើល្អមិនបានផលល្អពីអ្នកទទួលឡើយ ប្រកបអាជីពមិនបាន លូតលាស់ ប្រកាន់មុខការហួសពេក មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអាទិត្យ ។

### ថ្ងៃពុធ

មិនសូវចូលចិត្តដើរលេងផ្ទះគេ មានប្រក្រតីនឹងនរ ប្រកបរបរមិនបានធំទូលាយ ផ្ញើជីវិតដោយសារគេ ធ្វើការឃើត យ៉ាវណាស់ មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច ។

### ថ្ងៃព្រហស្បតិ៍

ចំពោះភេទស្រី ត្រូវការដោយកម្លាំងតណ្ហាប្រទង់ប្រទាញ អាចឱ្យភ្លេចកូនចៅបាន មានចិត្តអន្ទះសារ ឆាប់ខឹង ទឹកចិត្តរោលរាល ស្រដីជៀសជួសនាយអាយច្រើន មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃសុក្រ

មានហ្វូងហ្វាយច្រើន មានសេចក្តីរីករាយជាមួយក្រុមគ្រួសារ មានកិត្តិយសអាចឱ្យវង្សត្រកូលពឹងពាក់ស្នាក់ អាស្រ័យបាន អបអរសាទរចំពោះញាតិ មិត្តល្អនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសៅរ៍

គំនិតឆ្អិន ហើយល្អិតល្អន់ផង ចិត្តចេះស្លូនត្រង់ដល់មនុស្សគ្រប់ជាន់ថ្នាក់ អ្នកមានបុណ្យសក្តិមេត្រីស្រឡាញ់ បាន សុខសាន្តនៅក្នុងទីឋាន គំនិតខ្ពង់ខ្ពស់ មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ៥-មនុស្សកើតឆ្នាំរោង

### ថ្ងៃអាទិត្យ

មានញាតិមិត្តច្រើនចោមរោមស្រឡាញ់ សំបូរអំណាច បានសុខបរិបូរណ៍សម្បត្តិភ័ស្តុស្ថាន មានគេគោរពកោត ក្រែងទូទៅ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

មាត់អាក្រក់ អភ័ព្វសំដី មានបរិពារច្រើនមានពុត និយាយការយកជាសំខាន់មិនកើត ទៅកាន់ទីឆ្ងាយច្រើនមាន ទុក្ខរងទោសផ្សេងៗ ច្រើនមានការលាយឡំ អាក្រក់ជាល្អ សជាខ្មៅ មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃ ព្រហស្បតិ៍ ។

### ថ្ងៃអង្គារ

សម្តីច្រើនគំហ៊កកំហែង និយាយមិនសូវខ្លាចចិត្តគេ ចិត្តព្រហើនឈ្លានពាន មានប្រមាថច្រើន ជាមនុស្សលាក់ គំនួច មិត្តល្អនឹងមនុស្សកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអាទិត្យ ។

### ថ្ងៃពុធ

ច្រើនធ្លោយគំនិតធ្លាក់ខ្លួនទៅក្នុងមហន្តរាយ គិតអ្វីច្រើនមិនចេះដាច់ស្រេច មានសេចក្តីលំបាករឿយៗ ស្រេក ឃ្លានមិនខ្វាសអៀន មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍ ។

### ថ្ងៃព្រហស្បតិ៍

ខំធ្វើល្អច្រើនជួបឧបសគ្គរាំងដំណើរការ ច្រើនត្រូវប៉ះពាល់នឹងបច្ចាមិត្តដែលបំណងទុកយូរមកហើយ ច្រើនលំ បាកកាយ ចិត្តជាទុក្ខព្រោះគេបង្ខិតបង្ខំខុសទំនង ប្រយ័ត្នវេទមន្តគេ មិត្តល្អនឹងអ្នកកើតថ្ងៃអាទិត្យ សត្រូវនឹងអ្នកកើតថ្ងៃ អង្គារ ។

### ថ្ងៃសុក្រ

ច្រើនមានគេនិយាយបកស្រាយកេរ្តិ៍គ្រប់ទិសទី ការងារជាចាំបាច់ត្រូវបានគេបៀតបៀនកាត់មុខជានិច្ច ច្រើនមាន ពិការពុំស្រួលកាយរឿយៗ មានតែគេគុំប្រទូស្តជាដរាប មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសៅរ៍

មានអំណាចលើសលប់ មានគេជួយយកអាសារកាន់ជើង ចិញ្ចឹមខ្លួនដោយបរិសុទ្ធ ជាមនុស្សប្រាកដនិយម ជាទីគួរ ឱ្យស្ញប់ស្ញែងដល់សម្តីវោហារ មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

# ៦-មនុស្សកើតឆ្នាំម្សាញ់

## ថ្ងៃអាទិត្យ

ត្រូវគេចាក់ដោតមួលបង្កាច់ពាក្យញឹកញាប់នៅក្នុងភូមិផងរបងជាមួយគេ គេច្រើនស្អប់ឫក ច្រើនមានសេចក្តីរសាប់រសល់នៅក្នុងលំនៅដ្ឋានរបស់ខ្លួន ចិត្តធំច្រើនពុំចេះជិនឆ្អន់ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃ អង្គារ ។

## ថ្ងៃចន្ទ

ច្រើនបានសុខស្ងប់ទុកដោយនៅសម្ងំមិនចេញទៅណាឆ្ងាយ ត្រេកអរក្នុងកិរិយាសង្រួមរវាំងឥរិយាបថ ចេះលាក់កំបាំងកិច្ចការសារពើមិនឱ្យគេដឹង ខ្មាសអៀនច្រើន មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

## ថ្ងៃអង្គារ

ជួយឈឺឆ្អាលគេរមែងបានទទួលរងអំពើក្តៅក្រហាយ ខ្លួនមានកង្វល់គ្មានគេជួយអើពើ មានសេចក្តីព្រួយលំបាកមិនសូវបានលំហែ ចូលចិត្តដើរលេងច្រើន មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអាទិត្យ ។

## ថ្ងៃពុធ

ច្រើនសម្តែងឫកហួសចំណេះ ដំណើរវែងឆ្ងាយច្រើនបានទទួលផលអាក្រក់ អ្នកផងច្រើនទ្រលាន់ចិត្តនឹងអំពើដែល ខ្លួនធ្វើ ចិញ្ចឹមជីវិតដោយប្រកាន់មុខរបរតែម្យ៉ាង មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវតិចតួចនឹងអ្នកកើតថ្ងៃសៅរ៍ ។

## ថ្ងៃព្រហស្បតិ៍

មានគេជួយការពារគ្រប់យ៉ាង មានទីលំនៅច្រើនស្តុកស្តម្ភ គេតែងកោតសរសើររឿយៗ បានជាធំចម្បងក្នុងវង្ស ត្រកូលច្រើនបានជាទីពឹងជ្រកកោនញាតិមិត្ត មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសុក្រ

មានសេចក្តីកំណាញ់ស្វិតស្វាញពេក សំបូរទ្រព្យធន គិតតែប្រយោជន៍ផ្ទាល់ខ្លួន អាងអំណាចណាស់ មានសេចក្តី សន្តោសគេសម្តីសូញសាញ មិត្តល្អនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសៅរ៍

ចំពោះភេទប្រុសច្រើនអារីះគួព្រេង បើភេទស្រីច្រើនមានចិត្តល្មោភកាម គ្មានចិត្តអៀនខ្មាស ចិត្តចើកមារយា ក្នុងទីប្រជុំរំពៃលៃតែខាងផ្លូវកាម មានទុក្ខព្រោះកាមរោគរោលរាល មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃ ព្រហស្បតិ៍ ។

## ៧-មនុស្សកើតឆ្នាំមមី

### ថ្ងៃអាទិត្យ

មានកម្លាំងបរិបូរណ៍ មានឥស្សរភាពច្រើនក្នុងការងារ បរិបូរណ៍ទៅដោយសម្បត្តិទ្រព្យ អ្នកផងទូទៅកោតក្រែង ធ្វើរាជការមានសមត្ថភាពចំពោះកិច្ចការ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

មានវាសនាជាធំ មានអ្នកមានបុណ្យសក្តិ ឬ អំណាចឧបត្ថម្ភជួយជ្រោមជ្រែង បានប្រកបទៅដោយសេចក្តីសុខ ធ្វើរាជការកាន់មុខតំណែងខ្ពស់ នាយជាធំជឿទុកចិត្ត មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

### ថ្ងៃអង្គារ

បានជាទីប្រឹក្សានៃអ្នកកាន់អំណាចជាធំ មានឥទ្ធានុភាពលើសលប់វង្សត្រកូល ញាតិមិត្តចូលចិត្តជ្រកអាស្រ័យបុណ្យវាសនាបាន មិត្តនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

### ថ្ងៃពុធ

បុណ្យវាសនាមានស្មើវង្សត្រកូល ឬសំសួននឹងតម្រេះវិជ្ជាខ្លួន កិរិយាច្រឡើសបើសបន្តិច មារយាទមិនស្របតាមសេចក្តីប្រព្រឹត្ត អភ័ព្វក្នុងកិច្ចការសង្គ្រោះអ្នកដទៃ មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវបន្តិចបន្តួចនឹងអ្នកកើតថ្ងៃសៅរ៍ ។

### ថ្ងៃព្រហស្បតិ៍

បានជាអ្នកទទួលរក្សាមរតកវង្សត្រកូល នាហ្មឺន គហបតី ជួយបំពេញប្រយោជន៍រឿយៗ មានវាសនាល្មមចិញ្ចឹមអាត្មាបានដោយមិនត្រូវចំណាយញើសច្រើនទេ មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសុក្រ

ច្រើនជាមនុស្សកំព្រា ឬមិនសូវមានញាតិមិត្តច្រើន លំបាករកផ្លូវទុកដាក់ខ្លួនឱ្យសមរម្យ ច្រើនទញ់ទាល់គំនិតឬ គំនិតរាក់ គ្មានទីពឹងយ៉ាងកក់ក្តៅ គេអបអរថាតែមាត់ចិត្តទីទៃ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ

### ថ្ងៃសៅរ៍

ច្រើនមានពិការអវៈយវៈ ជាមនុស្សមិនសូវមានសេរីភាព ប្រកបមុខរបរច្រើនខកខាន ច្រើនមានវិបត្តិក្នុងទីកន្លែងអាស្រ័យនៅប្រក្រតី មានការធ្លោយគំនិតលង់ទ្រនេស ព្រោះគេដឹកនាំ មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើត ថ្ងៃព្រហស្បតិ៍ ។

## ៨-មនុស្សកើតឆ្នាំមមែ

### ថ្ងៃអាទិត្យ

ច្រើនប្រកបមុខរបរនៅដោយផ្សារ ពូកែរកប្រាក់មាស តែមិនសូវចេះទុកដាក់ សំបូរទៅដោយគ្រឿងបរិភោគ ច្រើនរកស៊ីលក់ដូរបានសំខាន់ មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

អ្នកមានសម្បត្តិ ឬអ្នកមានបុណ្យសក្តិផ្តល់សេចក្តីសុខឱ្យញឹកញយ បានសម្បត្តិបរិបូរណ៍ដោយអាជីវកម្មជំនួញ ញាតិមិត្តមានចិត្តស្រឡាញ់ ពេញអធ្យាស្រ័យណាស់ មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

### ថ្ងៃអង្គារ

មានសេរីភាពល្អជាងវង្សត្រកូល រកលាភផលបានសេចក្តីព្យាយាម ប្រកបអាជីវកម្មបានផលប្រសើរ លុះតែធ្វើដំណើរទៅរកដោយទីឆ្ងាយ មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

### ថ្ងៃពុធ

ជាមនុស្សមានគេស្ងួនគ្រងច្រើន មានស្មារតីខ្ជាប់ខ្ជួនណាស់ បញ្ញារហ័ស គំនិតល្អិតល្អន់ ទឹកចិត្តទោទន់ទៅខាងសីលមន្តវិជ្ជាការផ្សេងៗ ប្រកបការអាជីពខាងគ្រូប្រសើរ មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច

### ថ្ងៃព្រហស្បតិ៍

មានវាសនាដោយសារអ្នកមានអំណាចជួយត្រាប្រណី ច្រើនបានជាធំជាប្រធាន នៅរួមជាមួយចៅហ្វាយនាយៗ បំពេញផលប្រយោជន៍ឱ្យយ៉ាងធូនចិត្តដរាប មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃសុក្រ

ជាមនុស្សឯកោអនាថា ច្រើនទទួលទុក្ខដោយសារគំនិតខ្លួន មានមិត្តភក្តិមិនសូវចេះអត់ឱនឱ្យគ្នា ប្រកាន់ជឿគំ និតខ្លួនហួសលើកកម្ពស់មិនវាស់ប្រមាណ មិត្តល្អនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសៅរ៍

មានរោគច្រើន បញ្ញាអន់ខ្សោយ លំបាកកាយលំបាកចិត្តណាស់ មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

# ៩-មនុស្សកើតឆ្នាំវក

## ថ្ងៃអាទិត្យ

ច្រើនមានគេកោតញញើតចំពោះខ្លួន មានគេទទួលស្គាល់រាប់អានច្រើន វាសនាបានជាធំ ធ្វើការរាជការមានចិត្តស្មោះត្រង់និងចៅហ្វាយនាយ មានកិត្តិយសល្អ មិត្តជាមួយអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

## ថ្ងៃចន្ទ

ជាមនុស្សសាមញ្ញ ធ្វើល្អយ៉ាងណានៅទាស់ខុសអធ្យាស្រ័យអ្នកដទៃ ធ្វើការច្រើនមិនហើយ ចូលចិត្តបេះបោចប្រ ឡែងច្រើន ចាប់ផ្តើមកិច្ចការឧស្សាហ៍តែមួយរំពេច មិត្តជាមួយអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## អង្គារ

ច្រើនមានគេចោទប្រកាន់ដោយមួលបង្កាច់ សត្រូវចងគំនុំមិនសូវចេះរសាយ ច្រើនធ្វើកិរិយាចង់ឱ្យគេស្ញើចដោយ ខុសទំនងប្រកបកិច្ចការច្រើនរើរុះទម្លាក់ចោល មិនសូវជួបដល់លាភផលធំដុំឡើយ មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹង អ្នកកើតថ្ងៃអាទិត្យ ។

## ថ្ងៃពុធ

អ្នកមានសីលធម៌មេត្តាអាណិតស្រឡាញ់យកធ្វើជាញាតិមិត្ត មានវាសនាខ្ពស់ គំនិតវៃវាងចំណាប់ បញ្ញាភ្លឺស្វាងមានវិជ្ជាជីវៈទូលំទូលាយ មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច ។

## ថ្ងៃព្រហស្បតិ៍

អ្នកមានគុណវិជ្ជាអប់រំរក្សា ផ្តល់ផលប្រយោជន៍រឿយៗ មានវិជ្ជាជីវៈប្រសើរ មានកិត្តិស័ព្ទសុះសាយ ស្មារតីល្អ បញ្ញាច្រើន មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសុក្រ

មានសច្ចៈ សុចរិត យុត្តិធម៌ល្អ វាសនាខ្ពស់ បានជាធំ ជាទីជ្រកកោនវង្សត្រកូល រូបផាន់សមរម្យ ឬកពារថ្លៃថ្នូរ មិត្តល្អនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសៅរ៍

ច្រើនមានស្អុនការញ៉ើកញយ គេចោមនិន្ទាគ្រប់ទីកន្លែង ធ្វើអ្វីមិនសូវបានគេចូលចិត្ត ឬកោតសរសើរ មិត្តល្អជាមួយអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃពុធបន្តិចបន្តួច ។

# ១០-មនុស្សកើតឆ្នាំរកា

## ថ្ងៃអាទិត្យ

សំបូរអំណាច អ្នកកាន់អំណាចធំប្រគល់សិទ្ធិឱ្យ អាជីពរស់នៅប្រកបទៅដោយសេចក្ដីសុខ និងសំបូរ ច្រើនមានគេជួយសង្គ្រោះដរាប មិត្តនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

## ថ្ងៃចន្ទ

ការរស់នៅដោយខ្វះខាតរឿយៗ មានសេចក្ដីចង្អៀតចង្អល់ច្រើន គេមិនសូវយកចិត្តទុកដាក់ជួយធុរៈឡើយ ខំធ្វើល្អដល់គេៗមិនឃើញវិញ ទោះក្នុងសភាពណាក៏ដោយ មិត្តល្អនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

## ថ្ងៃអង្គារ

ច្រើនតាំងចិត្តប្រព្រឹត្តកិរិយាជាអ្នកលេងស៊ប់ កាលមានហេតុកើតឡើងហាក់ដូចជាមិនឃើញសេចក្ដីស្លាប់ ច្រើនប្រកួតចង់បានឈ្នះ ខ្វះការខ្មាសអៀន មិត្តនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ថ្ងៃពុធ

អ្នកមានធម៌សប្បុរសជួយទំនុកបំរុង សំបូរបញ្ញាណាស់ មារយាទរម្យទុំល្អ ចិត្តរាបសា ស្រឡាញ់ការសិក្សា ចរិយារៀបរយមានសណ្ដាប់ធ្នាប់ មិត្តនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច ។

## ថ្ងៃព្រហស្បតិ៍

ច្រើនប្រកបកិច្ចការស្អាតល្អ មិនសូវមានហេតុការណ៍សៅហ្មង សំបូរទ្រព្យធន ចិត្តទូលាយ ស្រឡាញ់ការបុណ្យ កុសលសប្បាយរីករាយច្រើន មានគេចោមរោមជួយយកអាសារសព្វកិច្ចការ មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នក កើតថ្ងៃអង្គារ ។

## ថ្ងៃសុក្រ

ច្រើនមានកាយគ្រាំគ្រាទុរាទុរន់ ច្រើនប្រមូលសេចក្ដីទុក្ខមកគ្បៀតខ្សៀក សំបូរទៅដោយសេចក្ដីព្រួយរំខាន ស្វែងរកទ្រព្យខ្វះការតស៊ូ មិត្តនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសៅរ៍

មានចាស់ទុំចូលចិត្តអាណិតស្រឡាញ់ច្រើន បានទទួលកេរ្តិ៍សម្បាច់តំណវង្សត្រកូល បានផលល្អរឿយៗក្នុងការធ្វើ គុណដល់គេ មិត្តល្អនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

## ១១-មនុស្សកើតឆ្នាំច

### ថ្ងៃអាទិត្យ

សង្វាតព្យាយាមច្រើន ប្រើកម្លាំងកាយពេញទំហឹង ទើបបានរស់រួចជីវិត ការងារធ្វើយ៉ាងមមាញឹកជួនបានផល ជួនមិនបានផល ប្រកបកិច្ចការច្រើនលំបាកបន្តិច មិត្តល្អនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃចន្ទ

បានទទួលការណែនាំអំពីអ្នកមានគុណវិជ្ជារឿយៗ សំបូរចំណេះវិជ្ជា ប្រកបកិច្ចការទាំងពួងតែងលំបាកខាងដើម ខាងក្រោយទើបបានប្រសើរ មិត្តល្អនឹងអ្នកកើតថ្ងៃពុធ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

### ថ្ងៃអង្គារ

រូបកាយច្រើនទៅដោយរោគ លំបាកនឹងប្រកបកិច្ចការឱ្យបានធំទូលាយ ពឹងពាក់គេមិនបានសមតាមបំណង គេឆាប់មើលងាយ តែចិត្តអង់អាចមិនចេះផុតរលត់ មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអាទិត្យ ។

### ថ្ងៃពុធ

មានគេចោមរោមជួយកិច្ចការធុរៈ មានសមត្ថភាពគ្រប់គ្រាន់ បរិបូរណ៏ទៅដោយលាភយស ប្រសើរលើសមិត្តភក្តិ ជាទីមេត្រី មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃព្រហស្បតិ៍

គំនិតច្រើនរវើរវាយ ធ្វើការលីនលន ពោលពាក្យទ្រគោះ ស្មារតីច្រើនវង្វេងភ្លេច បញ្ញាអន់ស្ញើយ ហ៊ានហួសខ្លាច ហួស មិត្តនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអង្គារ ។

### ថ្ងៃសុក្រ

មានកិត្តិយសប្រសើរ សំបូរសប្បាយច្រើន អ្នកមានបុណ្យសក្តិប្រកាន់ជឿទុកចិត្ត រកទ្រព្យបានដោយមធ្យោបាយ ត្រជាក់ មិត្តនឹងអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

### ថ្ងៃសៅរ៍

ត្រូវគេតម្រាមសំឡុតជាញឹកញយ មានទុក្ខទោសព្រោះជួយយកអាសារអ្នកធំ ឬអ្នកមានសម្បត្តិបរិបូរណ៏ទៅ ដោយគ្រឿងឧបភោគ បរិភោគ ច្រើនបានចាំយាមគយឃ្លាំងឱ្យនាយចៅហ្វាយ មិត្តនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។

# ១២-មនុស្សកើតឆ្នាំកុរ

## ថ្ងៃអាទិត្យ

អ្នកមានអានុភាពជាធំអាណិតស្រឡាញ់ជួយសង្គ្រោះ មានវាសនាគាប់ប្រសើរ ចូលទីពឹងនាហ្មឺនមន្ត្រីមានសេចក្តីមេត្តាជួយដោយមេត្រី រស់នៅដោយសុខសាន្ត រកលាភផលបានញឹកញយ មិត្តនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នក កើតថ្ងៃអង្គារ ។

## ថ្ងៃចន្ទ

មានគេបំប៉នដើម្បីគៃយកកំរៃផលពីខ្លួន ខាងដើមបានសេចក្តីសុខ ឆាប់ភ្លេចខ្លួននឹងអំពើល្បួងលួងបញ្ឆោតរបស់ សត្រូវគ្រាក្រោយច្រើនមានសេចក្តីទុក្ខព្រួយគ្របសង្កត់ មិត្តជាមួយអ្នកកើតថ្ងៃអង្គារ សត្រូវនឹងអ្នកកើតថ្ងៃសុក្រ ។

## ថ្ងៃអង្គារ

អ្នកមានភោគសម្បត្តិជួយឧបត្ថម្ភ មានចិត្តស្លូតត្រង់ទ្រព្យយ៉ាងជាប់ចិត្ត រកទ្រព្យបានចេះសំចៃលៃលក ប្រកបកិច្ចការបានផលល្អរឿយៗ រស់នៅជាមួយអ្នកណា អ្នកនោះមានសេចក្តីយោគយល់ក្រៃលែង មិត្តល្អនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃអាទិត្យ ។

## ថ្ងៃពុធ

ច្រើនរស់នៅដោយកម្លាំងខ្លួន ធ្វើគុណបំណាច់ដល់គេៗពុំដែលឱ្យផលតបវិញឡើយ ប្រកបការងារច្រើនមានសេច ក្តីរំខានទីពឹងមិនសូវសំខាន់ មិត្តល្អនឹងអ្នកកើតថ្ងៃចន្ទ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍បន្តិចបន្តួច ។

## ថ្ងៃព្រហស្បតិ៍

ច្រើនមានគំនិតចង់សប្បាយជ្រុលពេក រីករាយទាល់តែភ្លេចការងារប្រក្រតី ត្រេកអរនឹងទីកន្លែងធំទូលាយ ដើរទៅកាន់ទិសទីផ្សេងៗច្រើន មិត្តនឹងអ្នកកើតថ្ងៃសុក្រ សត្រូវនឹងអ្នកកើតថ្ងៃសៅរ៍ ។

## ថ្ងៃសុក្រ

ច្រើនមានរោគាពាធនៅក្បាល ច្រើនមានការប៉ះពារជំពប់ថ្លស់គ្រេចជើងដៃ ប្រកកិច្ចការមិនបានវែងឆ្ងាយ ឬធំ ទូលាយទុក្ខព្រួយដោយសារគេ មិត្តនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ សត្រូវនឹងអ្នកកើតថ្ងៃចន្ទ ។

## ថ្ងៃសៅរ៍

ច្រើនបានជាមេជាប្រធានលើគេ និងបានជាធំក្នុងវង្សត្រកូល មានគេរាប់អានយកជាមេត្រីគ្រប់ជាន់ថ្នាក់ មិត្តនឹងអ្នកកើតថ្ងៃជារាហ៊ូ សត្រូវនឹងអ្នកកើតថ្ងៃព្រហស្បតិ៍ ។